**សុន្ទរកថាគន្លឹះរបស់**

**ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ថ្លែងក្នុងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១**

**នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣**

**ថ្ងៃពុធ ១៣រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦**

**ត្រូវនឹងថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២**

**ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ**

**លោកស្រី អាលីសា ឆាគ័រ (Alissar Chaker) តំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំនៅកម្ពុជា!**

**លោក យី សុខថា (Yi Soktha) តំណាងមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ប្រចាំនៅកម្ពុជា!**

**លោក លឹម សាគី (Lim Saky) តំណាងយូនីសេហ្វ (UNICEF) ប្រចាំនៅកម្ពុជា!**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី**

១. ថ្ងៃនេះ ខ្ញុំមានសេចក្ដីរីករាយជាអនេក ដោយបានមកចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោស្រី ក្នុងសិក្ខាសាលាផ្សព្វផ្សាយ **របាយការណ៍វាយតម្លៃពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣** នាពេលនេះ។ យើងរៀបចំសិក្ខាសាលានាពេលនេះ ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជា បានគ្រប់គ្រងបានយ៉ាងល្អ និងទប់ទល់មិនឱ្យបន្តមានការរីករាលដាលនៃមេរោគកូវីដ-១៩ ជាពិសេស មេរោគបំលែងថ្មីអូមីក្រុង ដែលបានអំណោយផលយ៉ាងល្អដល់កម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ាន លើកទី

៤០ និង ៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ក្នុងនាមជាប្រធានអាស៊ានប្តូរវេន ឆ្នាំ២០២២ នេះ ។

២. ក្នុងនាមថ្នាក់ដឹកនាំក្រសួងផែនការ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានមកចូលរួមក្នុងសិក្ខាសាលានាពេលនេះ តាមការអញ្ជើញរបស់ក្រសួងផែនការ។ ជាមួយគ្នានេះ សូមអរគុណផងដែរចំពោះ ដៃគូអភិវឌ្ឍនានា ជាពិសេស កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) និង យូនីសេហ្វ (UNICEF) ដែលបានគាំទ្រ ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់ការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នេះ រួមទាំងដំណើរការនៃសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍នេះ នាពេលនេះ។

៣. ដូចឯកឧត្តម លោកជំទាវ លោក លោកស្រីជ្រាបហើយថា រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សិទ្ធិប្រទានដល់ក្រសួងផែនការសម្រាប់ដឹកនាំសម្របសម្រួល និងការរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*។ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធ ពីឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលតំណាងក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានា ក្នុងការផ្តល់ធាតុចូលសម្រាប់រៀបចំ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ នេះ និងការផ្តល់អនុសាសន៍ និងការបំពេញបន្ថែមលើសេចក្តីព្រាង នៅក្នុងកិច្ចប្រជុំអន្តរក្រសួង ទាំងកម្រិតបច្ចេកទេស និងកម្រិតនយោបាយ បានធ្វើឱ្យការរៀបចំរបាយការណ៍នេះទទួលបានជោគជ័យ ត្រូវបានបញ្ចប់ជាស្ថាពរ និងទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា នាថ្ងៃទី៣ ខែតុលា ឆ្នាំ២០២២ កន្លងទៅ។

៤. **របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នេះ** គឺជាលទ្ធផលនៃការវាយតម្លៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣* ក្នុងរយៈពេលពីរឆ្នាំកន្លះ ពីឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២១។ លទ្ធផលនៃការអនុវត្តផែនការជាតិនេះតាមវិស័យ ដែលសម្រេចបានដោយក្រសួង ស្ថាប័ននានា និងភាគីពាក់ព័ន្ធ នៅក្នុងរយៈ

ពេលពាក់កណ្ដាលអាណត្តិដំបូង ត្រូវបានបង្ហាញក្នុងរបាយការណ៍នេះ។ ការពិនិត្យមើលនិងវាយតម្លៃពី លទ្ធផលនៃការសម្រេចបាន ឬមិនសម្រេចបាន គឺជាការពិនិត្យមើលពីលទ្ធផលនៃការអនុវត្តជាក់ស្ដែង ធៀបនឹងគោលដៅគោលនយោបាយ និងផែនការ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ជាពិសេស ក្នុងជំពូកទី៣ និងទី៤។

៥. ការពិនិត្យនិងវាយតម្លៃពីលទ្ធផលនៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣* នេះ ក៏ត្រូវរួមបញ្ចូលផងដែរថា នូវបញ្ហាប្រឈមនានាដែលបានជួបប្រទះក្នុងអំឡុងពេលនៃការអនុវត្តផែនការ នេះ។ ផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ១៩ និងមេរោគបម្លែងថ្មីនានា មកលើដំណើរការនៃការអនុវត្ត និងលទ្ធផលនៃការអនុវត្តផែនការនេះ ក៏ត្រូវបានដាក់បញ្ចូលផងដែរក្នុងរបាយការណ៍នេះ។ ដោយឡែក ចំពោះលទ្ធផលនានានៃការអនុវត្តបណ្ដាគោលនយោបាយ ផែនការ តាមវិស័យ ដែលបានកំណត់នៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២* និងបញ្ហាប្រឈមនានា ដែលសម្រេចបាន និងជួបប្រទះ ក្រោយខែមិថុនា ឆ្នាំ២០២១ មិនត្រូវបានដាក់បញ្ចូលក្នុង របាយការណ៍ពាក់កណ្ដាលអាណត្តិនេះទេ។

## ឯកឧត្ដម លោកជំទាវ លោក លោកស្រី

៦. ជាការពិត ដោយសារការរីករាលដាលនៃមេរោគកូវីដ-១៩ លទ្ធផលនៃការអនុវត្ត *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២* ក្នុងរយៈពេលពាក់កណ្ដាលអាណត្តិដំបូងនេះ មិនទទួលបានលទ្ធផលល្អប្រសើរតាមការគ្រោងទុករបស់យើងទេ។ វត្តមានរបស់មេរោគកូវីដ-១៩ នៅកម្ពុជា ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២០ មក បានធ្វើប៉ះពាល់ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា រាំងស្ទះដល់ដំណើរការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា និងបានបង្អាក់ដំណើរការនៃការឈានទៅសម្រេចបានចក្ខុវិស័យរបស់កម្ពុជាដែលគ្រោងថា នឹងចាកចេញពីស្ថានភាពប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ហើយក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និង ក្លាយជាប្រទេសដែលមានចំណូលខ្ពស់ នៅឆ្នាំ២០៥០។

៧. នៅពេលបន្តិចទៀតនេះ ក្រុមការងារនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ ដឹកនាំដោយ **ឯកឧត្ដម ថេង បញ្ញាធន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុក អគ្គនាយក

ផែនការ នឹងធ្វើបង្ហាញជូន ពីលទ្ធផលនៃការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៩-២០២៣ ក្នុងរយៈពេលពាក់កណ្តាលអាណត្តិ ដំបូង ពីឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ ២០២១ និងបញ្ហាប្រឈមនានាដែលបានជួបប្រទះក្នុងអំឡុងពេលនៃការអនុវត្តនេះ ដែលបានដាក់បញ្ចូលក្នុង របាយការណ៍ពាក់កណ្តាលអាណត្តិ ដែលយើងកំពុងធ្វើការផ្សព្វផ្សាយនេះ ប៉ុន្តែ ខ្ញុំសូមអនុញ្ញាតពីអង្គសិក្ខាសាលា លើកឡើងដោយត្រួសៗជារួម នូវស្ថានភាពរួមនៃម៉ាក្រូសេដ្ឋកិច្ច ជាក់ស្តែង ដែលជាលទ្ធផលនៃការអនុវត្ត និងទទួលរងផលប៉ះពាល់ពីកត្តារាំងស្ទះផ្សេងៗ រួមទាំង ការរីករាលដាលនៃកូវីដ-១៩ ផងដែរ។

៨. កម្ពុជាបានជួបប្រទះនូវកំណើនសេដ្ឋកិច្ចអវិជ្ជមានលើកដំបូង ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ ក្នុងកម្រិត -៣,១% ក្នុងឆ្នាំ២០២០ ដែលមូលហេតុចម្បងបណ្តាលមកពីការរីករាលដាលនៃមេរោគកូវីដ-១៩ ប៉ុន្តែត្រឹមតែរយៈពេលខ្លី នៅឆ្នាំ២០២១ តែសេដ្ឋកិច្ចកម្ពុជាបានស្ទុះងើបឡើងវិញ មកត្រឹមកម្រិត ២,៤% នៅឆ្នាំ២០២១ ដែលជាលទ្ធផលនៃគ្រប់គ្រងការរីករាលដាលនៃមេរោគកូវីដ-១៩ បានយ៉ាងល្អរបស់រាជរដ្ឋាភិបាលកម្ពុជា រួមទាំង ការចាក់ស្រោចវ៉ាក់សាំងជូនប្រជាជនកម្ពុជា និងជនបរទេសគ្រប់រូបនៅកម្ពុជា ដោយឥតគិតថ្លៃ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងនេះ និងរួមទាំងការដាក់ចេញនិងអនុយុទ្ធសាស្ត្រស្តារសេដ្ឋកិច្ចក្រោយកូវីដ-១៩ ធនាគារអភិវឌ្ឍន៍អាស៊ីបានការព្យាករថា សេដ្ឋកិច្ចកម្ពុជាអាចនឹងកើនឡើងដល់ ៥,៥% នៅក្នុងឆ្នាំ២០២២។ នៅឆ្នាំ២០១៩ វិស័យដែលនាំមុខគេក្នុងសេដ្ឋកិច្ចកម្ពុជា គឺវិស័យឧស្សាហកម្ម ដែលបានរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបក្នុងកម្រិត ៣៨,៣% និង វិស័យសេវាកម្ម ដែលបានរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបក្នុងកម្រិត ៣៨,១%។ ទោះជាដូចនេះក្តី សេដ្ឋកិច្ចតាមវិស័យមានការធ្លាក់ចុះយ៉ាងខ្លាំង រួមទាំងវិស័យកម្មន្តសាល សំណង់ វិស័យទេសចរណ៍ និងវិស័យពាក់ព័ន្ធផ្សេងទៀត។

៩. ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ នៅក្នុងអំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ មានប្រមាណ ១ ៧០០ដុល្លារអាមេរិក ទន្ទឹមគ្នានឹងអតិផរណា បានកើនឡើងដល់ ៣,៤% ក្នុងត្រីមាសទី២ ឆ្នាំ២០២១ ប៉ុន្តែនៅតែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។ ចំណាយសាធារណៈមានចំនួនលើសចំណូលរបស់រដ្ឋ

ក្នុងកម្រិត ៧,២% និង ១១,៣% រៀងគ្នា។ ការរីករាលដាលនៃកូវីដ-១៩ បានធ្វើឱ្យប្រតិបត្តិការមូលធនអនុវត្តបានតែក្នុងកម្រិតមួយប៉ុណ្ណោះ និងបានធ្វើឱ្យប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ចទាំងមូល។ មេរៀនពីការរាំងស្ទះដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ នេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់សម្រាប់គ្រោងនូវវិធានការសមស្រប ដើម្បីជំរុញផលិតកម្មក្នុងរយៈពេលវែង។

១០. សន្ទស្សន៍បំណុលធៀបនឹងផលិតផលក្នុងស្រុកសរុប ត្រូវបានរក្សាឱ្យនៅក្នុងកម្រិតស្ថិរភាព គឺក្រោម ៣០%។ បើប្រៀបធៀបនឹងបំណុលសាធារណៈធៀបនឹងផលិតផលក្នុងស្រុកសរុបរបស់ប្រទេសថៃ មានកម្រិត ៥០,៥% ប្រទេសវៀតណាមមានកម្រិត ៤៦,៧% និងប្រទេសឡាវមានកម្រិត ៥៥,៦៦%។

១១. ដើម្បីធានានូវចីរភាពចំណូល រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមកៀរគរចំណូលតាមរយៈគោលនយោបាយចំណូលថ្មី និងក្របខណ្ឌស្ថាប័ន ដោយធ្វើការពង្រឹងការគ្រប់គ្រងចំណូល សវនកម្មពន្ធ និងធ្វើឱ្យប្រសើរឡើងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសដាក់ឱ្យប្រើប្រាស់យុទ្ធសាស្ត្រកៀរគរចំណូលជាមួយនឹងកម្មវិធីធ្វើទំនើបកម្មប្រព័ន្ធចំណូលសារពើពន្ធ ដើម្បីឆ្លើយតបទៅនឹងតម្រូវការកើនឡើងនៃគុណភាពសេវាកម្ម ការធានាសមធម៌សង្គម និងចីរភាពប្រាក់ចំណូល។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានពង្រឹងផងដែរនូវគោលនយោបាយសារពើពន្ធ និងគោលនយោបាយមិនមែនសារពើពន្ធ ក្នុងវិស័យសំខាន់ៗ។ ប្រាក់ចំណូលក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ ២០២១ មានចំនួន ៣,១៨ទ្រីលានរៀល មានការធ្លាក់ចុះ ប្រមាណ ១០,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ ដោយសារតែការធ្លាក់ចុះនៃពន្ធលើទំនិញ និងសេវា ដែលបណ្តាលមកពីការប្រើប្រាស់មានការធ្លាក់ចុះ។

១២. ស្ថានភាពជញ្ជីងទូទាត់មានអតិរេកជាមធ្យមប្រមាណ ៤% ធៀបនឹងផលិតផលក្នុងស្រុកសរុប នៅក្នុងរយៈពេលពីឆ្នាំ២០១៩ ដល់ឆមាសទី១ ឆ្នាំ២០២១។ នៅឆ្នាំ២០២០ ឱនភាពគណនីចរន្តបានថយចុះដល់ ៨% នៃផលិតផលក្នុងស្រុកសរុប ហើយនៅឆមាសទី១ ឆ្នាំ២០២១ ឱនភាពគណនីចរន្តបានបន្តកើនឡើង ដោយសារការកើនឡើងឱនភាពពាណិជ្ជ

កម្មទំនិញ និងចំណូលបឋម ស្របពេលដែលគណនីសេវាសុទ្ធបន្តមានឱនភាព។ ក្នុងឆមាសទី១ ឆ្នាំ២០២១ ឱនភាពពាណិជ្ជកម្មទំនិញបានកើនឡើងដល់ ៤២,៧% នៃផលិតផលក្នុងស្រុកសរុប ដែលបណ្តាលមកពីការនាំចូលកើនឡើងលឿនជាងការនាំចេញ។

១៣. ទុនបម្រុងអន្តរជាតិ ទោះបីជាមានការកើនឡើងពី ១៤,៦ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៨ ដល់ ២១,៣ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០២០ ក្តី ប៉ុន្តែដោយសារការចំណាយលើសលុបរបស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលកូវីដ-១៩ និងជួយសង្គ្រោះប្រជាជនក្នុងរយៈពេលនៃការរីករាលដាលនៃមេរោគនេះ ទុនបម្រុងអន្តរជាតិ បានថយចុះប្រមាណ ៥% មកត្រឹម ២០,២ប៊ីលានដុល្លារអាមេរិក នៅចុងខែមិថុនា ឆ្នាំ២០២១។ ទុនបម្រុងអន្តរជាតិ អាចធានាបានការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាន់ ប្រមាណ៩ខែ និងអាចអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអត្រាប្តូរប្រាក់ និងការផ្គត់ផ្គង់តម្រូវការសន្ទនីយភាពនិងរក្សាបានភាពធន់នៃ វិស័យហិរញ្ញវត្ថុ នៅពេលមានការប៉ះទង្គិចពីវិបត្តិសេដ្ឋកិច្ចជាយថាហេតុ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី

១៤. ជាទូទៅ ស្ថានភាពវិវត្តសង្គមសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ នៅក្នុងអំឡុងពេលពាក់កណ្តាលអាណត្តិដំបូងនៃផែនការ ពុំមានភាពល្អប្រសើរទេ ប៉ុន្តែដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងការរីរាលដាលកូវីដ-១៩ ការដាក់ចេញនិងអនុវត្តនូវវិធានការនានា រួមទាំងយុទ្ធសាស្ត្រស្តារអភិវឌ្ឍសេដ្ឋកិច្ច ក្រោយកូវីដ-១៩ បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាបាននឹងកំពុងកើនឡើងជាបណ្តើរៗ និងជាបន្តបន្ទាប់។ នៅពេលបញ្ចប់អាណត្តិរបស់ផែនការនេះ យើងរំពឹងថា ផលិតផលក្នុងស្រុកសរុបកម្ពុជានឹងកើនឡើងក្នុងកម្រិត ប្រមាណ ៦,២%។

១៥. ការងារចំពោះមុខរបស់យើងគ្រប់គ្នា គឺផ្តោតការយកចិត្តទុកដាក់លើ ការអនុវត្តនូវវិធានការគោលនយោបាយដែលត្រូវបានកែសម្រួលឬបន្តអនុវត្ត និងវិធានការគោលនយោបាយថ្មីៗដែលត្រូវលើកឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ កំណត់នៅក្នុងជំពូកទី៤ (ជំហានបន្ទាប់) របស់របាយការណ៍នេះ។

១៦.	ខ្ញុំជឿជាក់ថា របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ នេះ នឹងជួយបង្អុលបង្ហាញទិសដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងការអនុវត្តវិធានការគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមវិស័យ ដើម្បីជំរុញណើនកំណើនសេដ្ឋកិច្ចឱ្យបានកម្រិតខ្ពស់ឡើងវិញ ដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា និងសម្រេចបានទស្សនវិស័យរបស់កម្ពុជា ឆ្នាំ២០៣០ ក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ក្លាយជាប្រទេសដែលមានចំណូលខ្ពស់។ ម្យ៉ាងវិញទៀត ដោយសារនៅដើមឆ្នាំ២០២៣ ខាងមុខក្រសួងផែនការ នឹងដឹកនាំសម្របសម្រួល ក្នុងការរៀបចំផែនការជាតិថ្មី សម្រាប់អាណត្តិកាល ២០២៤-២០២៨។ ដូចនេះ ខ្ញុំក៏ជឿជាក់ផងដែរថា របាយការណ៍នេះ ក៏នឹងក្លាយជាឯកសារយោង សម្រាប់ផ្តួចផ្តើមកំណត់នូវគោលនយោបាយ យុទ្ធសាស្ត និងសកម្មភាព សម្រាប់ដាក់បញ្ចូលក្នុងផែនការថ្មីផងដែរ។

១៧.	ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះកិច្ចសហការដ៏មានតម្លៃ របស់**ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទាំងអស់ ដែលបានចំណាយពេលវេលាដ៏មមាញឹក មកចូលរួមក្នុងសិក្ខាសាលានេះ។ ខ្ញុំសង្ឃឹមថា សិក្ខាសាលារបស់យើងនាថ្ងៃនេះ នឹងទទួលបានលទ្ធផលល្អប្រសើរ ដូចការគ្រោងទុក។

១៨.	ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូនដល់**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ទាំងអស់** នូវពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមទទួលបានជោគជ័យនិងរីករាយ នៅក្នុងឱកាសទិវាឆ្លងចូលឆ្នាំសាកល ឆ្នាំ២០២៣ នាពេលខាងមុខនេះ កុំបីឃ្លាងឃ្លាតឡើយ។

១៩. ខ្ញុំសូមប្រកាសបើកជាផ្លូវការនូវ **សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**!